# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការពារជាតិ**

# ញត្តិគាំទ្រ

យើងខ្ញុំទាំងអស់គ្នា តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងអស់ សូមគាំទ្រទាំងស្រុង និងយ៉ាងពេញទំហឹង ចំពោះលទ្ធផលនៃការផ្ទៀងផ្ទាត់ផែនទី ដែលតំណាងអង្គការសហប្រជាជាតិ បាននាំយកមកប្រគល់ជូនរាជរដ្ឋាភិបាលកម្ពុជា ធ្វើការផ្ទៀងផ្ទាត់នាថ្ងៃទី ២០ ខែសីហា ឆ្នាំ២០១៥ នៅវិមានសន្តិភាព រវាងផែនទី ដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងប្រើបច្ចុប្បន្ន និងផែនទីរបស់អង្គការសហប្រជាជាតិ ឃើញថា មានភាពដូចគ្នា ដែលនេះបានបង្ហាញយ៉ាងច្បាស់អំពីភាពត្រឹមត្រូវពិតប្រាកដ នៃផែនទីដែលរាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងប្រើប្រាស់ ក្នុងការកំណត់ព្រំដែន រវាងកម្ពុជានិងវៀតណាម និងបង្ហាញឲ្យឃើញកាន់តែច្បាស់ អំពីនយោបាយបោកប្រាស់របស់ក្រុមជនអគតិមួយចំនួន ដែលតែងតែកុហក បោកប្រាស់ មួលបង្កាច់ខុសពីការពិតមកលើរាជរដ្ឋាភិបាលនាពេលកន្លងមក ហើយក៏កាន់តែបង្ហាញឲ្យឃើញកាន់តែច្បាស់ដោយឥតប្រកែកបាន អំពីនយោបាយបោកប្រាស់ក្នុងគោលបំណងបម្រើអាជីវកម្មនយោបាយដ៏ងប់ងល់ របស់ពួកខ្លួន ដោយមិនគិតអំពីផលប្រយោជន៍ដ៏ឧត្តុងឧត្តមរបស់ជាតិ មាតុភូមិ និងប្រជាពលរដ្ឋ។

ជាថ្មីម្តងទៀត តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងអស់ សូមប្រកាសគាំទ្រយ៉ាងឧឡារិក ចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ត្រឹមត្រូវប្រកបដោយគតិបណ្ឌិតខ្ពង់ខ្ពស់ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលតែងតែបានបូជា កម្លាំងកាយ កម្លាំងចិត្ត និងប្រកាន់ភ្ជាប់នូវឧត្តមគតិស្នេហាជាតិដ៏ឧត្តុងឧត្តម ក្នុងការការពារបូរណភាពទឹកដី និងអធិបតេយ្យជាតិ ជាពិសេសក្នុងការដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាង ប្រកបដោយការទទួលខុសត្រូវខ្ពស់ចំពោះជោគវាសនារបស់ប្រទេសជាតិនិងមាតុភូមិទាំងមូល។

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងអស់ សូមធ្វើការថ្កោលទោសយ៉ាងដាច់អហង្ការ ចំពោះ ទង្វើរបស់ជនអគតិមួយចំនួន ដែលតែងតែបានធ្វើការប្រឌិត និងចោទប្រកាន់មួលបង្កាច់ទាំងងិតងងល់ នាពេលកន្លងមក ដើម្បីបម្រើនយោបាយប្រជាភិថុតរបស់ក្រុមខ្លួន មកលើកិច្ចខិតខំប្រឹងប្រែងយ៉ាងស្មោះសរ និងដើម្បី ឧត្តមប្រយោជន៍ជាតិរបស់រាជរដ្ឋាភិបាលលើការងារព្រំដែននេះ និងសូមអំពាវនាវឲ្យមានការចាត់វិធានការផ្លូវច្បាប់ ឲ្យបានម៉ឺងម៉ាត់បំផុត ដើម្បីពង្រឹងនីតិរដ្ឋ ក្នុងគោលបំណងថែរក្សា សន្តិភាព ស្ថិរភាពសង្គម សណ្តាប់ធ្នាប់សាធារណៈ និងដើម្បីភាពសុខក្សេមក្សាន្តរបស់ប្រជាពលរដ្ឋ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍ **ទៀ បាញ់**

វិថីហ្សកឌឺមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារៈ ០២៣ ៨៨៣ ២៧៤ អ៊ីមែលៈ generalsec@mod.gov.kh